**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខ ៖ ៤៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្ដីពី**

**ការកែសម្រួលអនុក្រឹត្យលេខ ៤២ អនក្រ.បក**

**ស្ដីពី**

**ការបង្កើតអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញ**

**រាជរដ្ឋាភិបាល**

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ ជស/រកម/ ០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ

-យោងតាមសំណើរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ

**សម្រេច**

**មាត្រា មួយ.-** មាត្រា ៣ និងមាត្រា ៤ នៃអនុក្រឹត្យលេខ ៤២អនក្រ.បក ចុះថ្ងៃទី ០១ ខែកក្កដា ឆ្នាំ-១៩៩៨ ស្ដីពីការបង្កើតអគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវបានកែប្រែដូចតទៅ :

**មាត្រា ៣ ថ្មី.-** អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ តាមសេចក្ដីស្នើសុំរបស់ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ក្រោយពីបានពិគ្រោះយោបល់ជាមួយសមាជិក ក្រុមប្រឹក្សា-ធម្មនុញ្ញដែលមានវត្តមាន ។ អគ្គលេខាធិការ និងអគ្គលេខាធិការរងមានឋានៈស្មើនឹងរដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការ ។

**មាត្រា ៤ ថ្មី.-** អគ្គលេខាធិការដ្ឋាន មានអគ្គនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលមួយចំនួននិងនាយកដ្ឋាន ឬថ្នាក់ប្រហាក់ប្រហែលមួយចំនួនសម្រាប់ជួយការងារ ។ នាយកដ្ឋានចែកជាការិយាល័យ ។ នៅក្នុងកម្រិតឥណទាន ដែលបើកឱ្យចាយសម្រាប់ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ត្រូវជ្រើសរើស តែងតាំងបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាន តាមសំណើរបស់អគ្គលេខាធិការ ។ បុគ្គលិកទាំងអស់អាចជ្រើសរើសថ្មី ឬផ្ទេរពីស្ថាប័នរដ្ឋផ្សេងៗទៀតក៏បាន ។ មន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋាន នៃក្រុមប្រឹក្សាធម្មនុញ្ញមានប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗទៀតស្មើនឹងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានរដ្ឋសភា ។

**មាត្រា ពីរ.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រុមប្រឹក្សាធម្មនុញ្ញ និងរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មីនា ឆ្នាំ ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការ រាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១ និង មាត្រា២
- រាជកិច្ច ✓
- ឯកសារ-កាលប្បវត្តិ